**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១១ សរណ

# សារលិខិត
## ស្តីពី
## ការបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភលើកទី ២ ក្រោមកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា

***បងប្អូនជនរួមជាតិទាំងអស់ជាទីស្រលាញ់ និងជាទីនឹករលឹក!***

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង និងសូមជម្រាបជូនជនរួមជាតិទាំងអស់ឱ្យបានជ្រាបថា អនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គមលេខ ១៣៤/សហវ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២២ ស្តីពីយន្តការ និងនីតិវិធី នៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យក្នុងអំឡុងពេលមានសម្ពាធអតិផរណា, រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចដាក់ឱ្យដំណើការ **កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា** ដោយបានបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភលើកទី ១ រួចរាល់ កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ កន្លងមក ដែលគ្រួសារប្រជាពលរដ្ឋងាយរងហានិភ័យដែលត្រូវបានកំណត់អត្តសញ្ញាណ បានទៅបើកប្រាក់ឧបត្ថម្ភនៅបញ្ជរវីងនៅទូទាំងប្រទេស។

តាមការសន្យា, រាជរដ្ឋាភិបាលនឹងចាប់ផ្តើមបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភលើកទី២ ជូនគ្រួសារប្រជាពលរដ្ឋគោលដៅដែលបានកំណត់អត្តសញ្ញាណរួច **ចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣** នេះតទៅ។ អាស្រ័យហេតុនេះ ខ្ញុំសូមអញ្ជើញគ្រួសារងាយរងហានិភ័យដែលបានកំណត់អត្តសញ្ញាណទាំងអស់ **រួមទាំងគ្រួសារងាយហានិភ័យទទួលបានប្រាក់ឧបត្ថម្ភលើកទី១, គ្រួសារគោលដៅក្រោមកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ ដែលបានបិទបញ្ចប់ និងគ្រួសារងាយរងហានិភ័យដែលទើបបានកំណត់អត្តសញ្ញាណថ្មី និងបានផ្ទៀងផ្ទាត់ឈ្មោះនៅឃុំ/សង្កាត់រួចរាល់** ទៅបើកប្រាក់ឧបត្ថម្ភ នៅតាមបញ្ជរវីងណាមួយ ដែលនៅជិតកន្លែងបងប្អូនរស់នៅ ដើម្បីទទួលបានសាច់ប្រាក់ឧបត្ថម្ភលើកទី២ ពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ពិសេសនេះ កុំបីខាន។

ខ្ញុំសូមបញ្ជាក់ថា រាជរដ្ឋាភិបាលបានដាក់ចេញនូវអន្តរាគមន៍គាំពារសង្គមនានា ក្នុងអំឡុងពេលមានវិបត្តិ ក្នុងគោលបំណងជួយសម្រួលដល់ជីវភាពរបស់គ្រួសារប្រជាពលរដ្ឋកម្ពុជា ពិសេសគ្រួសារក្រីក្រ ងាយរងគ្រោះ និងងាយរងហានិភ័យ ដែលនេះស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការ **មិនបោះបង់នរណាម្នាក់ចោល** និងបានបង្ហាញយ៉ាងច្បាស់អំពីភាពជាម្ចាស់ការ និងភាពជាអ្នកដឹកនាំដ៏ប៉ិនប្រសប់របស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជាឱ្យកាន់តែរឹងមាំ និងប្រកបដោយភាពធន់, សមធម៌, និងបរិយាបន្ន។ រាជរដ្ឋាភិបាលនឹងបន្តយកចិត្តទុកដាក់អំពីសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា និងដាក់ចេញនូវអន្តរាគមន៍គាំពារសង្គមនានា ឱ្យបានទាន់ពេល តាមការចាំបាច់។

សម្រាប់ព័ត៌មានបន្ថែមអំពីការទទួលបានប្រាក់ឧបត្ថម្ភ សូមទាក់ទងអាជ្ញាធរឃុំ/សង្កាត់ដែលនៅជិតផ្ទះបងប្អូន ឬមូលនិធិជាតិជំនួយសង្គម តាមរយៈទូរសព្ទលេខ ០១៥ ២១៩ ៨៨៨ ឬ ០៩២ ២១៩ ៨៨៨។

ថ្ងៃសុក្រ ២រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ មេសា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**